# សហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង

**KHMER KAMPUCHEA KROM COMMUNITY-NORTH AMERICA**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM- L'AMÉRIQUE DU NORD**

## លិខិតចូលរួមមរណទុក្ខ

## ជូន

## ឯកឧត្តម ស៊ីន ស៊ូប៉ែរ្តី

## និងក្រុមគ្រួសាររបស់ឯកឧត្តម

សហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង សហសេវិក សមាជិក សមាជិកា និងក្នុងនាមខ្ញុំបាទផ្ទាល់ មានសេចក្តីតក់ស្លុត និង សោកស្តាយជាពន់ពេក ដោយបានទទួលពតិមានដ៏សង្វេគយ៉ាងខ្លាំង ក្នុងការទទួលអនិច្ចកម្ម របស់អ្នកស្រី **នេម៉ាត្វូឡា មច្ឆវ៉ា** នាថ្ងៃច័ន្ទ ១០រោច ខែ បឋមាសាធ ឆ្នាំកុរ នព្វស័ក ព.ស.២៥៥១ ត្រូវនឹងថ្ងៃទី ០៩ ខែ កក្កដា គ.ស.២០០៧ ដោយជរាពាធ នៅសាធារណរដ្ឋបារាំង តាមរយៈឯកឧត្តម ថាច់ សេដ្ឋា ។

យើងខ្ញុំបាទ សហសេវិក សមាជិក និងសមាជិកាសហគមន៍ខ្មែរកម្ពុជាក្រោម នៅឯនាយសមុទ្រ សូមចូលរួម មរណទុក្ខជាមួយឯកឧត្តម និង ក្រុមគ្រួសាររបស់ឯកឧត្តម ក្នុងគ្រាដ៏មហាលំបានេះ ។

យើងខ្ញុំបាទ សហសេវិក សមាជិក និងសមាជិកាសហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង សូម គោរពវិញ្ញាណក្ខ័ន្ធអ្នកស្រី **នេម៉ាត្វូឡា មច្ឆវ៉ា** នូវវិរភាព និងបូជនីយកិច្ចទាំងឡាយ ដើម្បីជាតិ និង សាសនា ។

សូមវិញ្ញាណក្ខ័ន្ធអ្នកស្រី អញ្ជើញទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ទីក្រុងឡូវែល សហរដ្ឋអាមេរិក ថ្ងៃទី ១២ ខែ កក្កដា គ.ស.២០០៧

**គិម ប.ម. សគល**

នាយកប្រតិបត្តិ

---

Website: www.khmerkromngo.org
Mailing address in the United States & Canada: P.O. Box 1836, Lowell, MA 01853 U.S.A.
E-mail: KKCpressoffice@yahoo.com